## ឧបសម្ព័ន្ធទី ៣ : ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាព : តារាងសកម្មភាពគោលនយោបាយទូទាំងវិស័យ ឆ្នាំ ២០០៦-១០

| វិសាលភាពគោលនយោបាយ និង យុទ្ធសាស្ត្រ | សកម្មភាព (ត្រឹមដើមឆ្នាំ ២០០៦) | សកម្មភាព (ពាក់កណ្តាលឆ្នាំ ២០០៨) | សកម្មភាព(ត្រឹមដើមឆ្នាំ ២០១០) |
|---|---|---|---|
| ផ្តល់ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិអោយបានច្បាស់លាស់ សម្រាប់វិស័យ និងអនុវិស័យ តាមរយៈការអនុម័តច្បាប់អប់រំ ។ | - ច្បាប់អប់រំត្រូវបានអនុម័តនៅចុងឆ្នាំ ២០០៦ | | |
| កែលំអការប្រមើលមើលជាមុន សម្រាប់រៀបចំផែនការហិរញ្ញវត្ថុរយៈពេលមធ្យម និងការគ្រប់គ្រង និងពិនិត្យតាមដានបែបវិមជ្ឈការ និងកែលំអអភិបាលកិច្ច និងប្រព័ន្ធនិយ័តកម្មតាមរយៈការបង្កើនតម្លាភាព និងគណនេយ្យភាពនៃធនធាន រួមទាំងជំនួយពីខាងក្រៅ ។ | - គណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកភាពលើក្របខ័ណ្ឌចំណាយចរន្ត និងមូលធនរយៈពេល ៥ ឆ្នាំសម្រាប់វិស័យអប់រំ ដែលស្ថិតនៅក្រោមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នៅចុងឆ្នាំ ២០០៦ ។<br>- កែលំអចំណាយថវិកា តាមរយៈការប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំ រៀងរាល់ ៣ ខែ ម្តង ។ | - ពិនិត្យឡើងវិញការរីកចម្រើនស្តីពីការបំពេញការងារហិរញ្ញវត្ថុ ដោយរដ្ឋាភិបាល/ក្រសួងអប់រំ យុវជន និងកីឡា ។<br>- ពិនិត្យឡើងវិញការរីកចម្រើន ស្តីពីការគាំទ្រថវិកា ដោយអ្នកផ្តល់ជំនួយ ដើម្បីជួយដល់ការប្រមើលមើលពីហិរញ្ញវត្ថុ ។<br>- កែលំអចំណាយថវិកា តាមរយៈការប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំ រៀងរាល់ ៣ ខែ ម្តង ។ | - កែលំអចំណាយថវិកា តាមរយៈការប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ រៀងរាល់ ៣ ខែម្តង ។ |
| ពង្រឹងប្រព័ន្ធពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ និង ផលប៉ះពាល់ រួមទាំងដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីគាំទ្រវិស័យអប់រំ ។ | - នាយកដ្ឋានទាំងអស់ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់កម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ សម្រាប់ផ្តល់ជូនដល់អ្នកពាក់ព័ន្ធទាំងឡាយ ។<br>- ពិនិត្យតាមដានសកម្មភាពគោលនយោបាយជាប្រចាំ និងធ្វើរបាយការណ៍ស្តីពីការរីកចំរើននានាសម្រាប់ក្រុមបច្ចេកទេសចំរុះវិស័យអប់រំ | - នាយកដ្ឋានទាំងអស់ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់កម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ សម្រាប់ផ្តល់ជូនដល់អ្នកពាក់ព័ន្ធទាំងឡាយ ។<br>- ពិនិត្យតាមដានសកម្មភាពគោលនយោបាយជាប្រចាំ និងធ្វើរបាយការណ៍ស្តីពីការរីកចំរើននានា សម្រាប់ក្រុមបច្ចេកទេសចំរុះវិស័យអប់រំ | - នាយកដ្ឋានទាំងអស់ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់កម្មវិធីសកម្មភាពជាអាទិភាពនីមួយៗ សម្រាប់ផ្តល់ជូនដល់អ្នកពាក់ព័ន្ធទាំងឡាយ ។<br>- ពិនិត្យតាមដានសកម្មភាពគោលនយោបាយជាប្រចាំ និងធ្វើរបាយ |

| | | | |
|---|---|---|---|
| | រៀងរាល់ ៦ ខែម្តង ។ | រៀងរាល់ ៦ ខែម្តង ។ | ការណ៍ស្តីពីការរីកចំរើននានាសម្រាប់ក្រុមបច្ចេកទេសចំរុះវិស័យអប់រំ រៀងរាល់ ៦ ខែម្តង ។ |
| ពង្រឹងប្រព័ន្ធពិនិត្យតាមដានហិរញ្ញវត្ថុនៅថ្នាក់រដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ តាមរយៈបង្កើនការបណ្តុះបណ្តាលដល់អង្គភាពគ្រប់គ្រងថវិកា ។ | - រៀបចំកម្មវិធីកសាងសមត្ថភាពពេញលេញសម្រាប់អង្គភាពគ្រប់គ្រងថវិកាទាំងអស់នៅឆ្នាំ ២០០៦ ដើម្បីពង្រឹងការពិនិត្យតាមដានការកសាងផែនការហិរញ្ញវត្ថុ និងកម្មវិធី ព្រមទាំងជំនាញសវនកម្ម ជាពិសេសកិច្ចបញ្ជិការគណនេយ្យសាធារណៈ ។<br>- អង្គភាពគ្រប់គ្រងថវិកានៅរដ្ឋបាលកណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលជាមូលដ្ឋានគ្រឹះសម្រាប់សវនកម្មផ្ទៃក្នុង ។ | - ពង្រឹងប្រព័ន្ធកិច្ចបញ្ជិការគណនេយ្យសាធារណៈនៃមូលនិធិរបស់រដ្ឋាភិបាលសម្រាប់ក្រសួងអប់រំទាំងមូល ត្រឹមឆ្នាំ ២០០៨ ។ | |
| ធានាថាអង្គភាពគ្រប់គ្រងថវិកាដែលបានបង្កើតឡើង ក្លាយជាអង្គភាពប្រតិបត្តិ និងមានប្រសិទ្ធភាព ហើយប្រព័ន្ធគ្រប់គ្រងសាលារៀន/គ្រឹះស្ថានសិក្សា និង ស្រុក-ខ័ណ្ឌ ត្រូវបានកែលំអ ដើម្បីធានាការអប់រំប្រកបដោយគុណភាព ។ | - រៀបចំកម្មវិធីបំប៉នដល់ថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀនលើការងារគ្រប់គ្រង ។<br>- រៀបចំកែសម្រួលសេចក្តីណែនាំដល់អង្គភាពគ្រប់គ្រងថវិកាថ្នាក់ស្រុក និង សាលារៀន ក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង ។ | | |
| ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និង គ្រប់គ្រងបុគ្គលិក ។ | - អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក ផ្អែកលើ ICT នៅថ្នាក់រដ្ឋបាលកណ្តាល និងខេត្ត-ក្រុង ដោយសម្របសម្រួលជាមួយក្រុម | | |

| | | | |
|---|---|---|---|
| | ប្រឹក្សាកំណែទម្រង់រដ្ឋបាល<br>- រៀបចំផែនការសកម្មភាព សម្រាប់ការគ្រប់គ្រងព័ត៌មានផ្អែកលើ ICT នៅគ្រប់លំដាប់ថ្នាក់ | | |
| កែលំអការអភិវឌ្ឍ និងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា តាមរយៈកំណែទម្រង់ស្ថាប័ន និងហិរញ្ញវត្ថុ ដែលបង្កអោយមានស្វ័យភាពប្រតិបត្តិការកាន់តែច្រើនឡើង និងសិទ្ធិរកប្រាក់ចំណូលសម្រាប់គ្រឹះស្ថានឧត្តមសិក្សា | | - ផែនការយុទ្ធសាស្ត្រសម្រាប់ឧត្តមសិក្សាត្រូវបានរៀបចំឡើងត្រឹមឆ្នាំ ២០០៨ គិតទាំងការកសាងសមត្ថភាពសម្រាប់នាយកដ្ឋានឧត្តមសិក្សា និង ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន ។ | |